ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ១១ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម - ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

- ក -

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រឹត្យ

២៧-៣-១៩៩៥ - ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៥/៣៣ .... ៤៦០

II- ទីស្ដីការគណៈរដ្ឋមន្ត្រី

១.អនុក្រឹត្យ

២៧-៣-១៩៩៥ - អនុក្រឹត្យលេខ ៣៥ អនក្រ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ៤៦១

២៨-៣-១៩៩៥ - អនុក្រឹត្យលេខ ៣៦ អនក្រ ស្ដីពីការផ្ទេរនិងតែងតាំងមន្ត្រីរាជការ ៤៦៨

២៨-៣-១៩៩៥ - អនុក្រឹត្យលេខ ៣៧ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៤៦៩

២៨-៣-១៩៩៥ - អនុក្រឹត្យលេខ ៣៨ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៤៧០

២៨-៣-១៩៩៥ - អនុក្រឹត្យលេខ ៣៩ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៤៧១

២៩-៣-១៩៩៥ - អនុក្រឹត្យលេខ ៤០ អនក្រ ស្ដីពីការតែងតាំងមន្ត្រីរាជការ ៤៧៣

២. សេចក្ដីសំរេច

២៧-៣-១៩៩៥ - សេចក្ដីសំរេចលេខ ៣២ សសរ ស្ដីពីការផ្ទេរសិទ្ធិ ៤៧៤

២៨-៣-១៩៩៥ - សេចក្ដីសំរេចលេខ ៣៣ សសរ ស្ដីពីការផ្ទេរសិទ្ធិ ៤៧៥

២៩-៣-១៩៩៥ - សេចក្ដីសំរេចលេខ ៣៤ សសរ ស្ដីពីការផ្ទេរសិទ្ធិ ៤៧៦

៣- សេចក្តីប្រកាស

២៧-៣-១៩៩៥ - សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០២ សប្រក ស្តីអំពីសេរីភាពការូបនីយកម្មក្នុងការនាំចេញអង្ករ.. ៤៧៧

III- ការងារបណ្តាក្រសួង

១- ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក- សេចក្តីសំរេច

២៧-៣-១៩៩៥ - សេចក្តីសំរេចលេខ ០០៥ សសរ.ហសវ ស្តីពីការបង្កើតគណៈកម្មការលក់ឡាយឡុងទំនិញឆាប់ខូចគុណភាព ៤៧៨

ខ- ប្រកាស

២៧-៣-៩៥ - ប្រកាសលេខ ០៤៧ សហវ.ប្រកប ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង ៤៨០

២៧-៣-១៩៩៥ - ប្រកាសលេខ ០៥៣ សហវ.ប្រកប ស្តីពីការផ្ទេរឥណទាន ៤៨១

២- ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

២៧-៣-១៩៩៥ - ប្រកាសលេខ ១៦៥ ពណបសប្រក ស្តីពីការដាក់អោយប្រើប្រាស់នូវរូបសញ្ញាក្រសួងពាណិជ្ជកម្ម ៤៨៣

៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

២៤_៣_១៩៩៥ - ប្រកាសលេខ ២៤២ ផកប្រក អនុញ្ញាតអោយលោក ស្រេន គឹមលី ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៤៨៤

២៤_៣_១៩៩៥ - ប្រកាសលេខ ២៤៣ ផកប្រក អនុញ្ញាតអោយលោក ឈូ ហាន ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ៤៨៥

២៤_៣_១៩៩៥ - ប្រកាសលេខ ២៤៤ ផកប្រក អនុញ្ញាតអោយលោក អ៊ុំ ហៀង ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ ៤៨៥

២៤_៣_១៩៩៥ - ប្រកាសលេខ ២៤៥ ផកប្រក អនុញ្ញាតអោយលោក ង៉ោ ចាក់ ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ៤៨៦

២៤_៣_១៩៩៥ - ប្រកាសលេខ ២៤៦ ផកប្រក អនុញ្ញាតអោយលោក អ៊ុំម ធន ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៤ សេះ ៤៨៦

២៤_៣_១៩៩៥ - ប្រកាសលេខ ២៤៧ ផកប្រក អនុញ្ញាតអោយលោក ធើត ធេន ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ ៤៨៧

២៤_៣_១៩៩៥ - ប្រកាសលេខ ២៤៨ ផកប្រក អនុញ្ញាតអោយលោក កៅ ណម ជនជាតិខ្មែរ
បើកដំណើរការរោងជាងផលិតទ្វារ បង្អួចដែក ៤៨៧

១៦_៣_១៩៩៥ -ប្រកាសលេខ ២៤៩ ផក.ប្រក អនុញ្ញាតអោយលោក ចាន់ ឡាំ ជនជាតិ ខ្មែរ
បន្តដំណើរការសិប្បកម្មកាត់កញ្ចក់ ៤៨៨

២៤_៣_១៩៩៥ - ប្រកាសលេខ ២៥០ ផកប្រក អនុញ្ញាតអោយលោក តាំង មុយសេង ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ ៤៨៨

២៤_៣_១៩៩៥ - ប្រកាសលេខ ២៥១ ផកប្រក អនុញ្ញាតអោយលោក ឈិន ឈៀន ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ ៤៨៨

២៤_៣_១៩៩៥ - ប្រកាសលេខ ២៥២ ផកប្រក អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមាន
លោក សយ គេងហាវ បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង
៨០ សេះ ៤៨៩

២៤-៣-១៩៩៥ - ប្រកាសលេខ ២៥៣ ផកប្រក អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមាន
លោក ម៉ែន គៀត បើកដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង
១៦,៥ .... ៤៤៩

២៥-៣-១៩៩៥ - ប្រកាសលេខ ២៥៧ ផកប្រក អនុញ្ញាតអោយលោក ឡេង ផាត ជនជាតិខ្មែរ
បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ៤៥០

២៥-៣-១៩៩៥ - ប្រកាសលេខ ២៥៨ ផកប្រក អនុញ្ញាតអោយលោក ស៊ុន សំអាង ជនជាតិខ្មែរ
បើកដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវពិសេស " សញ្ញារូបពាំងពាស " ៤៥០

២៥-៣-១៩៩៥ - ប្រកាសលេខ ២៥៩ ផកប្រក អនុញ្ញាតអោយលោក ឆួយ វ៉ាន ជនជាតិខ្មែរ
បន្តសិប្បកម្ម ឡអិដ្ឋ គ្បឿង.. ៤៥១

២៥-៣-១៩៩៥ - ប្រកាសលេខ ២៦០ ផកប្រក អនុញ្ញាតអោយលោក ណាប ប៉ាន ជនជាតិខ្មែរ
បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម ៤៥១

២៥-៣-១៩៩៥ - ប្រកាសលេខ ២៦១ ផកប្រក អនុញ្ញាតអោយលោក ស៊ុយ ឡុង ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ.............................. ៤៥១

២៥-៣-១៩៩៥ - ប្រកាសលេខ ២៦២ ផកប្រក អនុញ្ញាតអោយលោក ផៃ អ៊ិត ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ.............................. ៤៥២

២៥-៣-១៩៩៥ - ប្រកាសលេខ ២៦៣ ផកប្រក អនុញ្ញាតអោយលោក អ៊ុន សារិន ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២០ សេះ.............................. ៤៥២

២៥-៣-១៩៩៥ - ប្រកាសលេខ ២៦៤ ផកប្រក អនុញ្ញាតអោយអ្នកស្រី លី ហ៊ុយ ជនជាតិខ្មែរ
បន្តដំណើរការរោងជាងគ្រឿងដែក.. ៤៥៣

២៥-៣-១៩៩៥ - ប្រកាសលេខ ២៦៥ ផកប្រក អនុញ្ញាតអោយលោក ប៊ូ ណាំ ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ.............................. ៤៥៣

២៥-៣-១៩៩៥ - ប្រកាសលេខ ២៦៦ ផកប្រក អនុញ្ញាតអោយលោក លៀង គីមហៀង ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ.............................. ៤៥៤

៤. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

៣០-៣-១៩៩៥ - ប្រកាសលេខ ៣៣០ ប្រសកប ស្ដីពីការតែងតាំង និង ផ្លាស់ប្ដូរមន្ត្រីរាជការ ៤៩៥

៥. ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

២៨-៣-១៩៩៥ - ប្រកាសលេខ ០៧៣/៩៥ ពបប្រក អនុញ្ញាតឲ្យបើករកស៊ីរកប្រអប់ទស្សនីយ៍ការរបស់អ្នកស្រី អ៊ុន ហើរស្សរ ៤៩៦

២៩-៣-១៩៩៣ - ប្រកាសលេខ ០៧៥/៩៥ ពបប្រក ស្ដីពីការប្ដូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

២៩-៣-១៩៩៥ - ប្រកាសលេខ ០៧៤ ស្ដីពីការផ្ទេរមន្ត្រីរាជការ ៤៩៧

៣០-៣-១៩៩៥ - ប្រកាសលេខ ០៧៧/៩៥ ពបប្រក អនុញ្ញាតអោយលោកស្រី អ៊ុង ស៊ីស្រ៊ន បើកអាជីវកម្មរោងពុម្ពឈ្មោះ ឡូ ហេង ៤៩៨

៣០-៣-១៩៩៥ - ប្រកាសលេខ ០៨១/៩៥ ពបប្រក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការនៅមន្ទីរពត៌មានខេត្តកំពត ៤៩៩

៣០-៣-១៩៩៥ - ប្រកាសលេខ ០៨២/៩៥ ពបប្រក ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការមន្ត្រីរាជការ ៥០០

៣០-៣-១៩៩៥ - ប្រកាសលេខ ០៨៣/៩៥ ពបប្រក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ ៥០១

៣០-៣-១៩៩៥ - ប្រកាសលេខ ០៨៤/៩៥ ពបប្រក ស្ដីពីការយល់ព្រមនិងទទួលស្គាល់មន្ត្រីរាជការ ៥០២

៣១-៣-១៩៩៥ - ប្រកាសលេខ ០៨៧ ពប.ប្រក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ មន្ទីរពត៌មានរាជធានីភ្នំពេញ ៥០៣

៦. ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិង កីឡា

ប្រកាស

២៤-៣-១៩៩៥ - ប្រកាសលេខ ២០៦ អយកប្រក ស្តីពីការបង្រួមអនុវិទ្យាល័យឈូក និងវិទ្យាល័យ ឈូក អនុវិទ្យាល័យទូកមាស និងវិទ្យាល័យទូកមាសនៅខេត្តកំពត ៥០៦

២៤-៣-១៩៩៣ - ប្រកាសលេខ ២០៧ អយកប្រក ស្តីពីការកែប្រែឈ្មោះវិទ្យាល័យសាធារណរដ្ឋ តួបា មកជាវិទ្យាល័យ " ច្បារអំពៅ " ក្នុងស្រុកមានជ័យ រាជធានីភ្នំពេញ ... ៥០៦

៧. ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

២៩-៣-១៩៩៥ - ប្រកាសលេខ ៩២ ប្រក.វវសបុ ស្តីពីការប្រគល់សញ្ញាប័ត្រកិត្តិយសប្រចាំឆ្នាំ ១៩៩៤-៩៥ ជូនវរៈសិល្បករ សិល្បការិនី ៥០៧

៨. ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

២៧-៣-១៩៩៥ - ប្រកាសលេខ ៧០/៩៥ កធសប្រកាស ស្តីពីការតែងតាំងមន្ត្រីរាជការ ៥០៩

៩. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

២៩-៣-១៩៩៥ - ប្រកាសលេខ ២០៦ មស បរ ស្តីពីការតម្លើងថ្នាក់កាំបៀវត្សប្រចាំឆ្នាំ ៥១០

២៩-៣-១៩៩៥ - ប្រកាសលេខ ២០៧ មស បរ ស្តីពីការតាំងស៊ុបក្នុងក្របខ័ណ្ឌរដ្ឋ ៥១២

១០. ទីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

សេចក្តីជូនដំណឹង

២៥-៣-១៩៩៥ - សេចក្តីជូនដំណឹងលេខ ០៧ សកអ ស្តីពីការជូនដំណឹងដល់គ្រប់សហគ្រាស, ក្រុមហ៊ុន , រោងចក្រ សិប្បកម្មក្នុងរាជធានីភ្នំពេញ ៥១៣

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៣៩៥/៣៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល កម្ពុជា

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៥ ។

ក្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ដែលមានរាយនាមដូចខាងក្រោមនេះ ជាឧត្តមសេនីយ៍ឯក " ផ្កាយមាស ៣ " នៃកងរាជនគរបាល ជាតិកម្ពុជា :

១-ឯកឧត្តម **ឯម សំអាន**

២-ឯកឧត្តម **គៀង ម៉ាន**

៣-ឯកឧត្តម **ហួ សុខ**

៤-ឯកឧត្តម **យ៉េង ម៉ារឌី**

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II- ឯកសារគណៈរដ្ឋមន្ត្រី

១- អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៥ អនក្រ ស្តីពីការបង្កើតគណៈកម្មាធិការ ជាតិគ្រប់គ្រងគ្រោះមហន្តរាយ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងរិដ្ឋាន

សំរេច

មាត្រា ១ : បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម ៖

១-សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ ជាសហប្រធាន

២_សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ អនុប្រធាន

៣_សហរដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៤_សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ជាសមាជិក

៥_រដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន ជាសមាជិក

៦_រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

៧_រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន ជាសមាជិក

៨_រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក

៩_រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

១០_រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាសមាជិក

១១_រដ្ឋមន្ត្រី ក្រសួងផែនការ ជាសមាជិក

១២_រដ្ឋមន្ត្រី ក្រសួងពត៌មាន ជាសមាជិក

១៣_រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ជាសមាជិក

១៤_ប្រធាន កាកបាទក្រហមកម្ពុជា ជាសមាជិក

១៥_លោកអគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

មាត្រា ២ ៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានតួនាទី និងភារកិច្ចដូចតទៅ ÷

១_រៀបចំគោលការណ៍ចាំបាច់ ទាក់ទងនិងការគ្រប់គ្រងគ្រោះមហន្តរាយ ។

២_ផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រី ស្តីពីការបង្ការគ្រោះមហន្តរាយ ត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយ ការប្រតិបត្តិការនៅពេលមានគ្រោះមហន្តរាយ ការជំរុញ ការស្តារស្ថានភាពឡើងវិញដោយរាជរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា ព្រមទាំងការឧបត្ថម្ភពីភ្នាក់ងារអង្គការមិនមែនរដ្ឋាភិបាល និង អង្គការអន្តរជាតិនានា ។

៣_ណែនាំពីសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ ដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ហើយនិងស្ថាប័នដទៃទៀត ។

៤_ធ្វើសំណើទៅរាជរដ្ឋាភិបាល ស្តីអំពីសេចក្តីត្រូវការ និងការប្រើប្រាស់ធនធានដូចជា មូលនិធិ សំភារៈ មធ្យោបាយ ប្រេងឥន្ធនៈ និង សំភារៈចាំបាច់ដទៃទៀតសំរាប់បំរើដល់ការខូចខាតដោយគ្រោះមហន្តរាយ ។

៥_អំពាវនាវដល់ស្ថាប័នជាតិ ភ្នាក់ងារអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងនិងក្រៅប្រទេស និងសប្បុរសជនទាំងឡាយដទៃទៀត ដើម្បីចូលរួមសហការជាមួយគណៈកម្មាធិការនេះ ។

៦_អំពាវនាវដល់ស្ថាប័នជាតិដទៃទៀត ដើម្បីជួយផ្តល់អ្នកជំនួយការក្នុងសកម្មភាពនេះ ។

មាត្រា ៣ ៖ សមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវចូលរួមប្រជុំអោយបានទៀងទាត់តាមការកោះ អញ្ជើញរបស់ប្រធាន ។

មាត្រា ៤ ៖ រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបញ្ជាក់ច្បាស់ដូច មានក្នុងឧបសម្ព័ន្ធ ១ ។

មាត្រា ៥ ៖ តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ៖

ក_លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ ដឹកនាំដោយលេខាអចិន្ត្រៃយ៍មួយរូប ដែលកំណត់ដោយប្រធានគណៈ កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

ខ_លេខាធិការដ្ឋាននេះ ជាស្ថាប័នដោយឡែកចំណុះអោយទីស្តីការគណៈរដ្ឋមន្ត្រីដែលមានមន្ត្រី មកពីក្រសួងពាក់ព័ន្ធចូលរួមអនុវត្តការងារ ។

គ_លេខាធិការដ្ឋាននេះ ត្រូវអនុវត្តការងាររបស់ខ្លួនតាមការដឹកនាំរបស់គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

១_រៀបចំកម្មវិធីសំរបសំរួលការងារជាមួយស្ថាប័ននានា ដើម្បីបំណុះបណ្តាលជំនាញដល់សមាជិកគណៈកម្មាធិការ ជាតិគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង អប់រំផ្សព្វផ្សាយដល់សាធារណជន ។

២_ប្រមូលទិន្នន័យគ្រោះមហន្តរាយ ដើម្បីធ្វើជាមូលដ្ឋានក្នុងការវាយតំលៃប៉ាន់ស្មានអំពីការខូចខាត និងរៀបចំកម្មវិធីស្តារ និងកសាងឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ដោយសំរបសំរួលការងារជាមួយស្ថាប័ននានា អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

៣_រៀបចំកម្មវិធីសិក្សាស្រាវជ្រាវនៅតាមតំបន់ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ភ្លើងឆេះព្រៃ ជំងឺរាតត្បាត និងតំបន់ដែលរងគ្រោះដទៃទៀត ។

៤_រៀបចំផែនការជាយថាហេតុសំរាប់សង្គ្រោះជាបន្ទាន់ ដូចជា ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ អគ្គីភ័យ ភ្លើងឆេះព្រៃ ជំងឺរាតត្បាត និងគ្រោះមហន្តរាយដទៃទៀត ។

៥_ប្រកាសភាពអាសន្ន និងជូនពត៌មានដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងសាធារណជន អំពីគ្រោះមហន្តរាយដែលនឹងកើតមានឡើង ។

៦_ណែនាំទិសដៅ និងបច្ចេកទេស ដឹកនាំការងារដល់លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ។

៧_សំរបសំរួលជាមួយស្ថាប័ន និងអង្គការនានាដែលពាក់ព័ន្ធ ដើម្បីបង្កើតខ្សែសង្វាក់ទាក់ទងដល់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គ្រប់ខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ។

៨_ទំនាក់ទំនងការងារជាមួយស្ថាប័ន អង្គការនានា កាកបាទក្រហម និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ។

៩_សំរបសំរួលការងារជាមួយស្ថាប័ន អង្គការនានា ដើម្បីផ្តល់ជំនួយជួយជន្លៀស រកជំរកការពារសន្តិសុខ អប់រំសាធារណៈ និងរៀបចំកម្មវិធីផ្សេងៗទៀត ។

១០_ទទួលបន្ទុកកិច្ចការរដ្ឋបាលរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

១១_ជំរុញសកម្មភាពការងាររបស់មណ្ឌលសង្គ្រោះបន្ទាន់នៅពេលមានភាពអាសន្ន និងមុនពេលមានភាពអាសន្ន ។

១២_ធ្វើរបាយការណ៍ ថ្វាយ និងជូនដល់គណៈកម្មាធិការជាតិតាមតំរូវការ ។

ឃ_លេខាធិការដ្ឋាននេះមានផ្នែកទទួលខុសត្រូវការងារដូចខាងក្រោមនេះ :

- ផ្នែកបណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ទំនាក់ទំនងការងារ និងផ្តល់ពត៌មាន
- ផ្នែក គ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ សំរបសំរួល និងផ្គត់ផ្គង់ភស្តុភារ
- មជ្ឈមណ្ឌលសង្គ្រោះជាបន្ទាន់ និងការស្តារឡើងវិញ

មាត្រា ៦ : មជ្ឈមណ្ឌលប្រតិបត្តិការបន្ទាន់មាន ៣ក្រុមសំរាប់ទទួលខុសត្រូវការងារ នៅពេលមានគ្រោះមហន្តរាយ និងមានមុខងារដូចខាងក្រោម :

- ក្រុមសង្គ្រោះជន្លៀស និង ដឹកជញ្ជូនសំភារៈ
- ក្រុម ការពារសុខភាព ផ្តល់ជំនួយ និងរក្សាសុខមាលភាព
- ក្រុម ការពារសន្តិសុខ និងទំនាក់ទំនងការងារ

១.ក្រុម សង្គ្រោះ ជន្លៀស និង ដឹកជញ្ជូនសំភារៈ :

-ការងារជួយសង្គ្រោះ និងជន្លៀស : ត្រូវអនុវត្តការងារផ្អែកតាមស្ថានភាពនៃគ្រោះមហន្តរាយដែលកើតឡើង ហើយតម្រូវអោយមានការជួយសង្គ្រោះជាបន្ទាន់ បញ្ជូនមណ្ឌលត្រួតពិនិត្យត្រូវរៀបចំ (១) ក្រុមប្រតិបត្តិការជួយសង្គ្រោះ និង (២) ក្រុមផ្តល់របាយការណ៍ពីសេចក្តីត្រូវការនៃជំនួយសង្គ្រោះ ។ ចំនួននៃក្រុមជួយសង្គ្រោះអាស្រ័យទៅតាមតម្រូវការ និងប្រភេទនៃគ្រោះមហន្តរាយនៅតាមតំបន់ ។ ការជួយសង្គ្រោះត្រូវស្នើឡើងដោយគណៈកម្មាធិការថ្នាក់លើ ឬ អង្គការអន្តរជាតិនានា ។

-ការងារដឹកជញ្ជូន : ត្រូវគ្រប់គ្រងការដឹកនាំជញ្ជូន និងពិនិត្យលើលទ្ធភាពនៃការដឹកជញ្ជូនសំភារៈហើយធានាគុណ ភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់សំភារៈទាំងនេះនៅតាមតំបន់ដែលកើតគ្រោះមហន្តរាយ ។ រាល់សំណើទាំងឡាយ ដែលទាក់ទងទៅនឹងការដឹកជញ្ជូនសំភារៈត្រូវស្នើទៅក្រុមការងារដឹកជញ្ជូន ។ ក្រុមការងារដឹកជញ្ជូននេះក៏ទទួលខុសត្រូវក្នុងការដឹកជញ្ជូនសំភារៈពីតំបន់ជិតៗផងដែរ ។

២.ក្រុមការពារសុខភាព ផ្តល់ជំនួយ និងរក្សាសុខមាលភាព :

-ការងារការពារសុខភាព : រៀបចំបរិក្ខារសំរាប់ការពារសុខភាព បណ្តុះបណ្តាលបុគ្គលិកផ្នែកការពារសុខភាព ហើយនាំផ្គត់ផ្គង់សំភារៈចាំបាច់ដូចជា ថ្នាំពេទ្យ បរិក្ខារពេទ្យ ឈាម និង សំភារៈដទៃទៀតដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយ ។

-ការងារផ្តល់ជំនួយ និងរក្សាសុខមាលភាព : ផ្តល់ជំនួយដល់ប្រជាពលរដ្ឋដែលរងគ្រោះរៀបចំពង្រឹងសហគមន៍ដើម្បីជួយលើកស្ទួយជីវភាពរបស់សមាជិកនៃសហគមន៍នេះ ។

៣.ក្រុម ការពារសន្តិសុខ និងទំនាក់ទំនងការងារ :

-ការងារសន្តិសុខ : ត្រូវមានការចូលរួមពីកងកំលាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងអាវុធហត្ថជាតិ ដើម្បីសហការការពារសន្តិសុខ របៀបរៀបរយអាយុជីវិតប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិនៅតំបន់ដែលកើតមានគ្រោះមហន្តរាយ ។

-ការងារទំនាក់ទំនង : ត្រូវប្រើប្រាស់គ្រប់មធ្យោបាយដែលមាន និងជំនួយសង្គ្រោះពីភ្នាក់ងារនានាដើម្បីផ្តល់ដល់ផ្នែកគ្រប់គ្រងកិច្ចប្រតិបត្តិការគ្រោះមហន្តរាយ ។

មាត្រា ៧ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម :

- អភិបាលខេត្ត ក្រុង ជាប្រធាន
- អភិបាលរងទីមួយ ខេត្ត ក្រុង ជាអនុប្រធាន
- តំណាងក្រសួងដទៃទៀត ជាសមាជិក

មាត្រា ៨ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុងមានតួនាទី និងភារកិច្ចដូចខាងក្រោម :

១_អនុវត្តគោលការណ៍ដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ។

២_ផ្តល់យោបល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្តីពីការបង្ការគ្រោះមហន្តរាយ រាល់ ត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយ ការប្រតិបត្តិការនៅពេលមានគ្រោះមហន្តរាយ ការជំរុញការស្តារស្ថានភាពឡើងវិញ ដោយរាជរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា ព្រមទាំងការ ...អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ នានា ។

...គ្រប់គ្រងគ្រោះមហន្តរាយដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក

៤_ស្នើមូលនិធិ និងមធ្យោបាយសំភារៈពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៥_ធ្វើរបាយការណ៍ស្តីពីការខូចខាតដោយគ្រោះមហន្តរាយជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៦_រៀបចំកម្មវិធីបណ្តុះបណ្តាល ដើម្បីបង្កើនបច្ចេកទេសជំនាញដល់សមាជិក ។

៧_ណែនាំពីរបៀបគ្រប់គ្រងដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ ស្រុក ខ័ណ្ឌ ។

មាត្រា ៩ : សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ត្រូវចូលរួមប្រជុំអោយបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធាន ។

មាត្រា ១០ : លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង មានរចនាសម្ព័ន្ធគ្រប់គ្រងដូចគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រោមការដឹកនាំរបស់លេខាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ហើយស្ថិតនៅក្រោមការរៀបចំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង ។ លេខាធិការដ្ឋាននេះអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង ។

មាត្រា ១១ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខ័ណ្ឌ មានសមាសភាពដូចខាងក្រោម :

-អភិបាលស្រុក ខ័ណ្ឌ ជាប្រធាន

-អភិបាលរងទីមួយ ស្រុក ខ័ណ្ឌ ជាអនុប្រធាន

-ប្រធានការិយាល័យដទៃទៀត សមាជិក

មាត្រា ១២ : គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម :

១-អនុវត្តគោលការណ៍ដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ។

២-ផ្តល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង ពីស្ថានភាពគ្រោះមហន្តរាយ ។

៣-រៀបចំកម្មវិធីបណ្តុះបណ្តាលប្រជាពលរដ្ឋ ពីការគ្រប់គ្រងគ្រោះមហន្តរាយ ។

៤-រៀបចំការអប់រំ និងផ្សព្វផ្សាយជាសាធារណៈ ពីគ្រោះថ្នាក់នៃគ្រោះមហន្តរាយ

៥-ស្នើអ្នកជំនួយការ ពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ដើម្បីដឹកនាំកិច្ចប្រតិបត្តិការពេលមានគ្រោះមហន្តរាយ ដូចជា ការសង្គ្រោះ ជម្លៀស រកទីជំរក និងរកជំនួយថ្នាំពេទ្យ ។

៦-ធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ពីស្ថានភាពនៃគ្រោះមហន្តរាយ ។

មាត្រា ១៣ : សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក ខ័ណ្ឌ ត្រូវចូលរួមប្រជុំ អោយបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធាន ។

មាត្រា ១៤ : លេខាធិការដ្ឋាននេះ មានរចនាសម្ព័ន្ធ និងតួនាទីដូចគណៈកម្មាធិការគ្រប់ គ្រងគ្រោះ មហន្តរាយថ្នាក់ខេត្ត ក្រុង ក្រោមការដឹកនាំរបស់លេខាធិការអចិន្ត្រៃយ៍មួយរូបដែលកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក ខ័ណ្ឌ ។ លេខាធិការដ្ឋាននេះអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់ ស្រុក ខ័ណ្ឌ ។

មាត្រា ១៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងយុទ្ធជន

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ថាមពល និងរ៉ែ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ប្រធានកាកបាទក្រហមកម្ពុជា ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៦ អនក្រ
ស្តីពីការផ្ទេរ និង តែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **សួន រិនឌី** ជាអភិបាលខ័ណ្ឌដូនពេញ រាជធានីភ្នំពេញជំនួសលោក **ប៉ាសុជាតិវង្ស** ដែលត្រូវផ្ទេរអោយទៅបំពេញការងារថ្មីនៅទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និង អស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៧ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង បណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ។

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ ជូនចំពោះសប្បុរសជន ដែលមានសទ្ធាជ្រះថ្លាបានផ្តល់អំណោយសំរាប់កសាងរាជធានីភ្នំពេញ និង ជួយសង្គ្រោះប្រជារាស្ត្រដែលជួបប្រទះគ្រោះធម្មជាតិ ដូចមានរាយនាមខាងក្រោម ÷

ក.ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ១ ៖

១_សមាគមចិននៅកម្ពុជា ទឹកប្រាក់ ៧៤.៩១៥ ដុល្លារអាមេរិក

ខ.ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ២ ៖

១_សមាគមពេចបិតាវ ព្រះបរិលិក តៃវ៉ាន់ ទឹកប្រាក់ ៦.០០០ ដុល្លារអាមេរិក

គ.ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ៖

១_លោកស្រី **លីម ស៊ីណា** ប្រធានសហគ្រាសផលិតទឹកកកចាក់អង្រែ ផ្តល់ម៉ាស៊ីនកុំព្យូទ័រ ០២ គ្រឿងអស់ប្រាក់ ៤៣៨៤ ដុល្លារអាមេរិក

២_លោក **ភុក អាន** ប្រធានក្រុមហ៊ុនអានកូ ផ្តល់ម៉ាស៊ីនកុំព្យូទ័រ ០២ គ្រឿងអស់ប្រាក់ ៤.៣៨៤ ដុល្លារអាមេរិក

៣_លោក **ឫទ្ធី ហេង** ក្រុមហ៊ុន សាំងឡេង ឧបត្ថម្ភសំភារៈការិយាល័យដល់សង្កាត់ទឹកល្អក់ទី ២ អស់ទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក ។

មាត្រា ២ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៨ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងបណ្ណស្ថាបនាជាតិ

-តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះលោក **លី ហួរ** និងលោកស្រី **កែវ សេខ** ព្រមទាំងបុត្រ ជនជាតិ ខ្មែរ នៅសហរដ្ឋអាមេរិកដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនអស់ ចំនួន ១៨.០០០ ដុល្លារអាមេរិក សំរាប់កសាងអគារសិក្សា ០២ ខ្នងនៅសាលាបឋមសិក្សា ព្រៃចំណារ ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្ត ស្វាយរៀង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្ត ស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួល លទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៩ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លា បានផ្តល់ អំណោយសំរាប់ជួយឧបត្ថម្ភដល់ជីវភាពប្រជារាស្ត្រក្រីក្រនៅឃុំ តាំងក្រាំង ស្រុកបាធាយ ខេត្ត កំពង់ចាម ឃុំ អង្គ តាសូ ស្រុក ស្វាយរៀង និង ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ :

ក.ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ១ :

១-ឧត្តមសេនីយ៍ **ម៉ា ឈឿន** និងលោកស្រី **អ៊ឹក ម៉ាលី** នៅក្រសួងមហាផ្ទៃ ទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក

២-លោកស្រី **ឈុន លាង** ក្រុមហ៊ុនវឌ្ឍនៈ ទឹកប្រាក់ ២៨ លានរៀល

ខ.ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ២ :

១-ក្រុមហ៊ុន **ហ៊ួ ឡុង** អង្ករ ២២ តោន មានតម្លៃ ២២.០៥០.០០០ រៀល

២-លោកស្រី **លាង ឈាង** និង លោកស្រី ក្រុមហ៊ុនជីម៉ិច ទឹកប្រាក់ ៥.២០០ ដុល្លារអាមេរិក

៣-លោក **សុខ លាង** និង លោកស្រី ក្រុមហ៊ុន **សុខ លាង** ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

៤-លោក **ដួង ឈីង** និង លោកស្រី ក្រុមហ៊ុន **ដួង ឈីង** ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

៥-លោក **ប៉ាង ណាំ** និង លោកស្រី ក្រុមហ៊ុន **ប៉ាង ណាំ** ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

គ.ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ៣ :

១-ក្រុមហ៊ុន **ម៉ៅ សាយគីម** ទឹកប្រាក់ ៨.៨៥០.០០០ រៀល

២-ក្រុមហ៊ុន **លីម សំបូរ** ទឹកប្រាក់ ៨.១៥០.០០០ រៀល

៣-ក្រុមហ៊ុន **ហួលីដេ** ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

៤-លោក **ម៉េង សេងខួចសម្បត្តិ** ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

៥-លោក **សិរិទ្ធ** ក្រុមហ៊ុនទតរសិរិទ្ធ ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

៦_លោក **កាយ សេង** និង លោកស្រី ក្រុមហ៊ុន **កាយ សេង** ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

៧_ក្រុមហ៊ុន **មៀង លីហេង** ទឹកប្រាក់ ៣.០០០.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤០ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង លោក **ទឹម៉ន ថាន់លី** ជានាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង លោក **ម៉ែន ថាន់លី** ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

២. សេចក្ដីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៩៩៥

សេចក្ដីសំរេចលេខ ៣២ សសរ

ស្ដីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមការងារចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរភារកិច្ចជូនឯកឧត្ដម **ឈា ថាំង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជារដ្ឋមន្ត្រីស្ដីទីក្រសួងផែនការ នៅក្នុងឱកាសដែលឯកឧត្ដម **ជា ចាន់តូ** អញ្ជើញទៅបំពេញបេសកកម្មនៅឯបរទេស ចាប់ពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥ រហូតដល់ពេលឯកឧត្ដមអញ្ជើញត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមខាងលើ ត្រូវទទួលបន្ទុកអនុវត្តភារកិច្ចនេះ រៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា ។

នាយករដ្ឋមន្ត្រីទី ១

ព្រះរាជហស្តលេខា

នរោត្តម រណឫទ្ធិ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៤

សេចក្តីសំរេចលេខ ៣៣ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមតំរូវការចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ចន្ទ ម៉ូលីចន្ទ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារវប្បធម៌ និងនគរូបនីយកម្ម ជារដ្ឋមន្ត្រីស្តីទីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួសឯកឧត្តម **គាត ឈន់** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅឯបរទេស ចាប់ពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៤ រហូតដល់ពេលឯកឧត្តមអញ្ជើញត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខាធិជ័ត្រា	ហត្ថលេខាធិជ័ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៤

សេចក្តីសំរេចលេខ ៣៤ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមការចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **អ៊ឹង គៀត** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ជារដ្ឋមន្ត្រីស្តីទីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជំនួសឯកឧត្តម **អ៊ុំងហួត** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅឯបរទេស ចាប់ពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៤ រហូតដល់ពេលឯកឧត្តមត្រលប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ | **ហ៊ុន សែន**

***

៣. សេចក្តីប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៩៩៥

សេចក្តីប្រកាសលេខ ០២ សរប្រក. របស់រាជរដ្ឋាភិបាលស្តីអំពីសេរីភាវូបនីយកម្ម ក្នុងការនាំចេញអង្ករ

កន្លងមក រាជរដ្ឋាភិបាលតែងយកចិត្តទុកដាក់ខំប្រឹងប្រែងក្នុងការជំរុញបង្កើន ផលិតកម្មស្រូវ ដើម្បីធានាអោយបាននូវស្វ័យភាពខាងស្បៀង និងលើសពីនេះទៀតអាចមានការ នាំចេញអង្ករ ថែមទៀតផង ។

អនុវត្តតាម ស្មារតីនៃគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលសំរាប់ឆ្នាំ ១៩៩៥ និង អនុស្សារណៈព្រមព្រៀងជាមួយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ស្តីពីការប្រកាសលុបចោលនូវការហាមឃាត់ក្នុងការនាំចេញអង្ករ និង ដោយយល់ឃើញថា ការធ្វើសេរីភាវូបនីយកម្ម នាំចេញអង្ករ គឺជាកត្តាគន្លឹះក្នុងការរួមចំណែកជំរុញអោយមានកំណើនផលិតកម្មស្រូវទូទាំងប្រទេស រាជរដ្ឋាភិបាលសូមធ្វើសេចក្តីប្រកាសដូចតទៅ ÷

១. លុបចោលនូវគោលការណ៍នៃការហាមឃាត់ការនាំចេញអង្ករ

២-ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធដទៃទៀតត្រូវសហការគ្នារៀបចំ និង លើកឡើងនូវវិធានការលំអិតជាក់ស្តែង ដើម្បីអនុវត្តគោលនយោបាយនេះដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

៣-ក្រោយពេលមានការលើកឡើង នូវវិធានការលំអិតជាក់ស្តែង ពីសំណាក់អន្តរក្រសួងពាក់ព័ន្ធរួចហើយរាជរដ្ឋាភិបាលនឹងធ្វើការពិនិត្យ និង ដាក់ចេញនូវសេចក្តីសំរេចសំរាប់អនុវត្តដែលត្រូវចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៥ តទៅ ។

៤-ចាប់ពីថ្ងៃប្រកាសផ្សាយនេះ រហូតដល់ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៥ ត្រូវអនុវត្តតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ដែលមានចុះក្នុងសេចក្តីជូនដំណឹង របស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ២០៧៦ សជណ.ពាហ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៤ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

III . ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១. សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ០០៥ សសវ.សហវ

ស្តីពីការបង្កើតគណៈកម្មការលក់ឡាយឡុង

ធំនិញនាច់ខ្ទង់គុណភាព

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញមាត្រា ១៦ នៃច្បាប់ស្តីអំពីពន្ធលើទំនិញនាំចេញ និងនាំចូល ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៨ ។

-បានឃើញកំណត់ហេតុល្មើសច្បាប់គយលេខ ០០១-៩៥ ឥរកសន របស់សាខាទីចាត់ការគយនិងរដ្ឋាករក្រុងព្រះសីហនុ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : បង្កើតគណកម្មការដើម្បីលក់ឡាយឡុងទំនិញជាប់ខូចគុណភាព ដែលមានសមាសភាព ៖

-លោក **ស ហួរ**	នាយកទីចាត់ការគយ និងរដ្ឋាករ	ជាប្រធាន
-លោក **កាំង លាងខ័ណ្ឌ**	អនុប្រធាននាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ	ជាអនុប្រធាន
-លោក **ស ថេង**	ប្រធានសាខាគយនិងរដ្ឋាករ ក្រុងព្រះសីហនុ	ជាសមាជិក
-អ្នកស្រី **កែ ម៉ានីរ៉ុង**	ប្រធានការិយាល័យតម្លៃ	ជាសមាជិក
-លោក **គិន លី**	អនុប្រធានការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ	ជាសមាជិក
-អ្នកស្រី **ឯក ម៉ាយ**	អនុប្រធានការិយាល័យគណនេយ្យ	ជាសមាជិក
-លោក **ជា ហាក់**	អនុប្រធានការិយាល័យវិវាទច្បាប់	ជាសមាជិក
-លោក **ជា អៀងម៉េង**	មន្ត្រីនាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ	ជាសមាជិក

ប្រការ ២ : គណកម្មការនេះមានភារកិច្ចរៀបចំនីតិវិធី និងលក្ខខ័ណ្ឌក្នុងការចូលរួមដេញថ្លៃរបស់អតិថិជនអោយបានសមស្រប ជាមុនហើយធ្វើការប្រកាសផ្សាយជាសាធារណៈរយៈពេល ៧ ថ្ងៃ ។

ប្រការ ៣ : ទំនិញដែលត្រូវអោយលក់ឡាយឡុងដោយគណកម្មការនេះមាន :

៣.១ - បារី ៥៥៥ (ល្អ) ចំនួន ២.០០០ប៊ិច (ខ្ទះពីរសុង)

- បារី 7 DIAMAND (ល្អ) ចំនួន ៤.១១៧ ប៊ិច (ខ្ទះដប់ប្រាំសុង)

- បារី UNHILL (ល្អ) ចំនួន ៧០ ប៊ិច

- បារី ROYAL (ល្អ) ចំនួន ៣០ ប៊ិច

៣.២ - ទំនិញផ្សព្វផ្សាយពាណិជ្ជកម្ម ចំនួន ៩១ កញ្ចប់

ប្រការ ៤ : ទឹកប្រាក់ទាំងអស់ដែលបានមកពីការលក់ដេញថ្លៃត្រូវបង់ចូលរតនាគារជាតិ ។

ប្រការ ៥ : ទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបណ្តាអស់លោកលោកស្រី ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ។

ទេសរដ្ឋមន្ត្រីទទួលបន្ទុកទិតិសម្បទានិងអភិវឌ្ឍន៍

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

* * *

២. ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤៧ សហវ.ប្រក.ប
ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីបញ្ជីក្របខ័ណ្ឌក្រសួង

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញប្រការ ៥នៃសេចក្តីសំរេចលេខ ០២ សសរ ៨៣ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៨៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និង សេចក្តីណែនាំអនុវត្តលេខ ២៣២ ផកបព ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៨៣ របស់ក្រសួងផែនការ ស្តីពីការឈប់សំរាករបស់មន្ត្រីរាជការដោយគ្មានច្បាប់អនុញ្ញាត ឬគ្មានមូលហេតុលើសពី ១៥ ថ្ងៃ ត្រូវចាត់ទុកថា បានបោះបង់ចោលការងារ និង អាចលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌរាជការ

-តាមសំណើរបស់នាយកដ្ឋានបុគ្គលិក

សំរេច

មាត្រា ១ : លុបឈ្មោះលោក **យឹម សុខា** ចេញពីបញ្ជីក្របខ័ណ្ឌ អតីតការៈបេសកកម្មផ្ទាល់របស់ ឯកឧត្តម **សម រង្ស៊ី** ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៥ ។

មាត្រា ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភរបស់សាមីខ្លួន ត្រូវបង្វិលចូលថវិការដ្ឋវិញចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៥ ។

មាត្រា ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

គាត ឈន់

***

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៥៣ សហវ.ថប្រក

ស្តីពីការផ្ទេរកំណាធាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥

-បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥

-បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុង ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥

-បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥

-តាមសំណើរបស់ព្រះបរមរាជវាំង លេខ ០៧២ វរលស ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិ នៅក្នុងរង្វង់ថវិកា របស់ព្រះបរមរាជវាំង សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការផ្ទេរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា ១០០០ រៀល

ស្ថានភាពឥណទានចាស់						ស្ថានភាពឥណទានថ្មី		
ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ការកត់ត្រាឥណទាន	ឥណទានអនុម័ត ឆ្នាំ ១៩៩៥	ការកែប្រែ កើន	ការកែប្រែ ថយ	ឥណទានថ្មី
				ការបង្វែរពីជំពូកទី ១១			១២០,០០០	
១១	០១	០៤		ក្រដាសបោះពុម្ព និង	៦០០,០០០		១២០.០០០	៤៨០.០០០
				សំភារៈការិយាល័យ				
				ផលប្រយោជន៍ជំពូកទី ១១		១២០.០០០		
១១	០១	០៨	០១	សោហ៊ុយទទួលភ្ញៀវបរទេស	៥.០០០	៣៥.០០០		៤០.០០០
១១	០២	០២	០២	សោហ៊ុយបេសកកម្ម				
				ក្រៅប្រទេស	៥.០០០	៥០,០០០		៥៥.០០០
១១	០២	០២	០៤	សោហ៊ុយផ្សេង ៗ	០	៣៥.០០០		៣៥.០០០

ប្រការ ២ : រដ្ឋមន្ត្រីព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អនុរដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ឆាយ ថន

* * *

២. ធីសិ្តការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៤៥ ពណបល.ប្រក

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- ឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល។

-យោងតាមសេចក្តីត្រូវការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ដាក់អោយប្រើប្រាស់នូវរូបសញ្ញាក្រសួងពាណិជ្ជកម្ម ដែលមានក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយនេះ ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៥ នេះតទៅ ។

ប្រការ ២ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក និងប្រធានអង្គភាពទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួង ត្រូវអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

***

៣- ឯកសារឯកសាររដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ២៤២ ឧក.ប្រក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក ស្រេន គីមលី ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១១៤៨៤ ក.ណ ចុះថ្ងៃទី ២៦-១២-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកំពង់ស្វាយលើ ឃុំ ព្រែកថ្មី ស្រុកកោះធំ ខេត្ត កណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក ស្រេន គឹមលី ត្រូវបន្តដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ២៤៣ ផក.ប្រក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក យូ មាន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៥៥៦៨៥ ក.ណ ចុះថ្ងៃទី ១៦-៥-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ក្បាលជ្រោយ ឃុំ ឈើខ្មៅ ស្រុកកោះធំ ខេត្ត កណ្តាល បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក យូ មាន ត្រូវបន្តដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ២៤៤ ផក.ប្រក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក អ៊ុំ ហៀង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១០៩១៣៦ ក.ណ ចុះថ្ងៃទី ១២-៩-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ព្រែកតាគង់ ឃុំ ព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្ត កណ្តាល បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក អ៊ុំ ហៀង ត្រូវបន្តដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ២៤៥ ផក.ប្រក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៥

